# អនុសាសន៍ ស្តីពីនីតិវិធីក្នុងការជ្រើសរើស និងការតែងតាំងសមាជិក នៃគណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត និងគណៈកម្មការថ្នាក់ក្រោមផ្សេងទៀត

យើងខ្ញុំទាំងអស់គ្នាជាតំណាងគណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលសូមជំរាបមក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)ថា ក្នុងកិច្ចប្រជុំថ្ងៃទី០៣ ខែមេសា ឆ្នាំ ២០១៣ នៅសណ្ឋាគារ សាន់វ៉េ បានយល់ព្រមគ្នាស្នើអនុសាសន៍ថាៈ

**គ.ជ.ប គួរអនុវត្ត "នីតិវិធីនៃការជ្រើសរើសសមាជិកគណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោតឲ្យមានលក្ខណៈបើកចំហរជាសាធារណៈ និងតម្លាភាព ជាពិសេសតំណែងប្រធាន និងអនុប្រធានគណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត និងកំឡុងពេលនៃការទទួល និងឈប់ទទួលពាក្យឲ្យបានយ៉ាងហោចរយៈពេល១០ថ្ងៃ"**។ ដោយយោងតាមសេចក្តីជូនដំណឹងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) លេខ ១១៥ និង១១៦ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៣ បានឲ្យដឹងថា ចំពោះតំណែងប្រធានគណកម្មការខេត្តរៀបចំការបោះឆ្នោតនៅគ្រប់ខេត្តទាំងអស់ ពុំមានការប្រកាសជ្រើសរើស រីឯតំណែងអនុប្រធានគណៈកម្មការខេត្តរៀបចំការបោះឆ្នោតនៅខេត្តមួយចំនួន ក៏ពុំមានការប្រកាសជ្រើសរើសដែរ រីឯរយៈពេលនៃការទទួល និងឈប់ទទួលពាក្យការជ្រើសរើសសមាជិកគធ/ខបមានត្រឹមតែ៥ថ្ងៃប៉ុណ្ណោះ។

មានការព្រួយបារម្ភពីនីតិវិធីក្នុងការជ្រើសរើសសមាជិកនៃគណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោតមិនមានភាពស្មើគ្នា តម្លាភាពដែលមានចែងក្នុងបទបញ្ជា និងនីតិវិធីសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥។ ប្រការ៣.១៩ ក្នុងជំពូកទី៣ "ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ" នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥ ២០១៣ ក៏បានលើកឡើងទៀតថា " **នីតិវិធីជ្រើសរើសមន្ត្រី បុគ្គលិកនៃគ.ជ.ប សមាជិក និងបុគ្គលិកនៃគធ/ខប គឃ/សប សមាសភាព គកប/គករ ត្រូវឈរលើគោលការណ៍ដោយស្មើភាព ដោយត្រឹមត្រូវ តម្លាភាព អព្យាក្រឹត្យភាព មិនប្រកាន់និន្នាការនយោបាយ សមត្ថភាព.............**"។

អនុសាសន៍នេះមានន័យថា គ្រប់តំណែងសមាជិកគណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត និងគណៈកម្មការថ្នាក់ក្រោមផ្សេងទៀតដែលត្រូវជ្រើសរើស និងតែងតាំងដោយមានតម្លាភាព នឹងបើកចំហរដែលយ៉ាងហោចតំណាងគណបក្សនយោបាយដែលមានអសនៈក្នុងសភាគួរត្រូវបានអនុញ្ញាតិដោយគ.ជ.ប ដើម្បីត្រួតពិនិត្យការជ្រើសរើស និងការតែងតាំងនេះ។

គ.ជ.ប គួរទទួលពិចារណានូវការស្នើសុំខាងលើនេះ ដើម្បីបង្កើនជំនឿលើការជ្រើសរើស និងការតែងតាំងសមាជិកទាំងអស់នៃគធ/ខប និងគណៈកម្មការថ្នាក់ក្រោមផ្សេងទៀត។

ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖


| | | |
|---|---|---|
| កញ្ញា គង់ រ៉ាវីន | អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល | ០១២ ៦៥ ៤៩ ៥០ |
| លោក សួន យុធ្យា | មន្ត្រីច្បាប់ខុមហ្វ្រែល | ០៨៨ ៨១៤ ២៧៨៣ |